ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន

ខែធ្នូ ឆ្នាំ២០១៦

# អារម្ភកថា

ប្រព័ន្ធអប់រំកម្ពុជាមានការរីកចម្រើនយ៉ាងខ្លាំងក្នុងការផ្តល់ឱកាសឱ្យកុមារគ្រប់អាយុចូលរៀន ជាពិសេស សម្រាប់កុមារនៅកម្រិតបឋមសិក្សា។ ទោះបីជាយ៉ាងនេះក្តី លទ្ធផលនៃការវាយតម្លៃការសិក្សារបស់សិស្សានុសិស្សនៅថ្នាក់ទី ៣ ទី ៦ និងទី ៨ និងលទ្ធផលនៃការប្រឡងមធ្យមសិក្សាទុតិយភូមិកាលពីបីឆ្នាំចុងក្រោយនេះ បង្ហាញថា ក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់ត្រូវចាត់វិធានការកំណែទម្រង់សំខាន់ៗ ដើម្បីធានាឱ្យកម្ពុជាអាចសម្រេចបានសកលកម្មនៃការអប់រំកម្រិតមូលដ្ឋានទាំងអស់គ្នាប្រកបដោយគុណភាព។ ជាការពិតណាស់ថា មានកត្តាជាច្រើនប្រទាក់ក្រឡាយ៉ាងជិតស្និទ្ធ ដែលប៉ះពាល់ដល់ដំណើរការរៀន និងបង្រៀន និងគុណភាពសិក្សារបស់សិស្ស។ ទោះបីជាយ៉ាងនេះក្តី មានការទទួលស្គាល់ជាសកលថា គុណភាពគ្រូបង្រៀនជាកត្តាដែលមានទម្ងន់ជាងកត្តានានាទាំងអស់ ជាពិសេសនៅក្នុងបរិបទដែលសកម្មភាពរៀនសូត្ររបស់សិស្សមានតែនៅក្នុងសាលារៀន ដូចករណីក្នុងប្រទេសកម្ពុជា។ គ្រូបង្រៀនអាចជាអ្នកធានាប្រសិទ្ធភាព និងគុណផលនៃការសិក្សារបស់សិស្ស តែនៅពេលណាដែលគ្រូបង្រៀនបានទទួលការអប់រំ និងបណ្តុះបណ្តាលត្រឹមត្រូវ និងគ្រប់គ្រាន់ពីប្រព័ន្ធអប់រំគ្រូបង្រៀនដែលធានាគុណភាព។

ចាប់តាំងពីដើមឆ្នាំ ១៩៨០ កម្ពុជាបានអនុវត្តប្រព័ន្ធបណ្តុះបណ្តាលគ្រូដែលមានលក្ខណៈខុសៗគ្នាច្រើនទម្រង់ ដែលរាប់ចាប់តាំងពីការបណ្តុះបណ្តាលពីរបីខែ រហូតដល់ពីរឆ្នាំ (១២+២)។ ឥឡូវនេះដល់ពេលដែលកម្ពុជាត្រូវពង្រឹងប្រព័ន្ធអប់រំគ្រូបង្រៀនឱ្យកាន់តែទំនើបដោយប្រែក្លាយកម្មវិធីបណ្តុះបណ្តាលដែលមានរយៈពេលពីរឆ្នាំ ទៅជាកម្មវិធីអប់រំដែលមានរយៈពេលបួនឆ្នាំវិញ។ ការធ្វើបច្ចុប្បន្នភាពនៃកម្មវិធីអប់រំគ្រូបង្រៀននឹងឆ្លើយតបទៅនឹងកំណែទម្រង់កម្មវិធីសិក្សា ដែលតម្រូវឱ្យលោកគ្រូ អ្នកគ្រូ ត្រូវផ្លាស់ប្តូរវិធីបង្រៀនដែលផ្អែកលើសៀវភៅពុម្ពមកជាការបង្រៀន ដែលទាមទារឱ្យលោកគ្រូ អ្នកគ្រូបង្កើតសម្ភារឧបទេសខ្លួនឯងឱ្យសម្បូរបែប ដោយផ្អែកលើសមត្ថភាព និងចំណង់ចំណូលចិត្តសិក្សារបស់សិស្ស។

ដើម្បីធានាឱ្យមានការយល់ឃើញដូចៗគ្នាក្នុងចំណោមអ្នកផ្តល់កម្មវិធីអប់រំគ្រូបង្រៀន ការរៀបចំស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន(TEPS) គឺជាការចាំបាច់។ ស្តង់ដានេះ នឹងជួយឱ្យគណៈគ្រប់គ្រងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម សាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ រៀបចំផែនការអភិវឌ្ឍគ្រឹះស្ថានរបស់ខ្លួនឱ្យទៅជាវិទ្យាស្ថានអប់រំគ្រូបង្រៀន ដោយឆ្លើយតបទៅនឹងស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀនផង ក្របខ័ណ្ឌគុណវុឌ្ឍិជាតិផង និងស្តង់ដាជាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សាផង។ គ្រឹះស្ថានឧត្តមសិក្សាក៏អាចនឹងប្រើប្រាស់ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន ដើម្បីរៀបចំពង្រីកសេវាគ្រឹះស្ថានរបស់ខ្លួនក្នុងការផ្តល់កម្មវិធីអប់រំគ្រូបង្រៀនផងដែរ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំថា ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀននឹងមានសារប្រយោជន៍ជួយគាំទ្រដល់កំណែទម្រង់គ្រូបង្រៀនលើផ្នែកផ្សេងៗទៀត ដូចជា ការជ្រើសរើស និងការ

បណ្តុះបណ្តាលដែលសង្កត់ធ្ងន់លើសមត្ថភាពរបស់គរុនិស្សិត ដែលនឹងត្រូវទៅបង្រៀនតាមសាលារៀននានា ដើម្បីឱ្យសិស្សទទួលបានកញ្ចប់សមត្ថភាពដូចការរំពឹងទុកនៅក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស។

ជាទីបញ្ចប់ ខ្ញុំសូមឆ្លៀតឱកាសនេះ អញ្ជើញភាគីពាក់ព័ន្ធឱ្យសហការគ្នា ដើម្បីប្រែក្លាយសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម សាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ឱ្យទៅជាវិទ្យាស្ថានអប់រំគ្រូបង្រៀន ដោយសង្កត់ធ្ងន់លើការបង្កើនគុណវុឌ្ឍិ សាស្ត្រាចារ្យ និងបំណិនគរុកោសល្យដែលផ្អែកវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល និងអភិវឌ្ឍសម្ភារឧបទេសសម្រាប់សាស្ត្រាចារ្យស្រាវជ្រាវក្នុងនាមពួកគាត់ជាអ្នកសិក្សាពេញមួយជីវិត។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

## ១. សារបាន

ដើម្បីធានាសម្រេចក្តីស្រមៃប្រែក្លាយកម្ពុជា ឱ្យទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិត ខ្ពស់ត្រឹមឆ្នាំ២០៣០ កម្ពុជាត្រូវការមូលធនមនុស្សដែលមានសមត្ថភាពពេញលេញ សម្រាប់បម្រើឱ្យគ្រប់វិស័យ។ ការអប់រំប្រកបដោយគុណភាពធ្វើឱ្យពលរដ្ឋមានសមត្ថភាពសម្រាប់ជំរុញកំណើនសេដ្ឋកិច្ច បង្កើនសមត្ថភាពប្រកួតប្រជែង ពង្រឹងជំនាញពាក់ព័ន្ធសម្រាប់ផ្លាស់ប្តូរសង្គម បង្កើតមូលដ្ឋាននៃកំណើនចីរភាពសេដ្ឋកិច្ចក្នុងប្រទេស និងនិរន្តរភាពនៃការអភិវឌ្ឍ និងរៀបចំមូលដ្ឋានគ្រឹះសម្រាប់ការផ្សារភ្ជាប់សង្គមឱ្យរឹងមាំ។

ចំណុចចាប់ផ្តើមនៃការអប់រំ គឺការអប់រំគ្រូបង្រៀន។ គ្រូបង្រៀនមិនត្រឹមតែដឹកនាំការផ្លាស់ប្តូរការអប់រំទៅរកគុណភាពប៉ុណ្ណោះទេ ប៉ុន្តែផ្លាស់ប្តូរទាំងទម្លាប់ និងជីវិតសិក្សារបស់សិស្សនៅគ្រប់កម្រិត និងគ្រប់ទម្រង់។ ដូច្នេះ ការអប់រំគ្រូបង្រៀន ជាកាតាលីករ និងគន្លឹះចម្បងមួយ ដើម្បីរៀបចំគរុនិស្សិតឱ្យក្លាយជាគ្រូបង្រៀនដែលមានគុណភាពប្រកបដោយចំណេះដឹង ជំនាញ និងសីលធម៌វិជ្ជាជីវៈ ដើម្បីបង្រៀនសិស្សឱ្យទទួលបានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងគុណតម្លៃ ដូចការរំពឹងទុកក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងការអប់រំបច្ចេកទេសតាមភូមិសិក្សានីមួយៗ។

ដើម្បីបំពេញតម្រូវការអាទិភាពនៃការលើកកម្ពស់គុណភាពអអប់រំ គ្រូបង្រៀនក្នុងប្រព័ន្ធអប់រំបច្ចុប្បន្នដែលមានគុណវុឌ្ឍិក្រោមបរិញ្ញាបត្រនឹងត្រូវបំប៉នបន្ថែម ដើម្បីឱ្យពួកគាត់មានគុណវុឌ្ឍិបរិញ្ញាបត្រលើមុខវិជ្ជាឯកទេសដែលត្រូវបង្រៀន តាមរយៈកម្មវិធីពន្លឿនវិក្រិតការរយៈពេលខ្លី។ កំណែទម្រង់ក៏តម្រូវឱ្យធ្វើបច្ចុប្បន្នភាពនៃប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀនពី ១២+២ ទៅជាកម្មវិធីបរិញ្ញាបត្រសម្រាប់គ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ ការផ្លាស់ប្តូរគោលនយោបាយបណ្តុះបណ្តាលគ្រូបង្រៀនតម្រូវឱ្យសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម សាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ត្រូវពង្រឹងទាំងមូលដ្ឋានសម្ភារៈ បុគ្គលិករដ្ឋបាល និងសាស្ត្រាចារ្យ ដើម្បីក្លាយជាគ្រឹះស្ថានឧត្តមសិក្សា [វិទ្យាស្ថានអប់រំគ្រូបង្រៀន] ដោយឆ្លើយតបទៅតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងស្តង់ដាជាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា។

កំណែទម្រង់ការអប់រំគ្រូបង្រៀន ក៏បើកឱកាសឱ្យគ្រឹះស្ថានឧត្តមសិក្សាចូលរួមចំណែកពង្រឹងគុណភាពអប់រំ តាមរយៈការផ្តល់កម្មវិធីអប់រំគ្រូបង្រៀន ដើម្បីចូលរួមចំណែកលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនឱ្យទទួលបានការអប់រំយ៉ាងតិចកម្រិតបរិញ្ញាបត្រ។ ដើម្បីធានាឱ្យបាននូវការយល់ដឹងជាទូទៅក្នុងចំណោមភាគីពាក់ព័ន្ធដែលបានចាប់អារម្មណ៍ ក្នុងការផ្តល់កម្មវិធីអប់រំគ្រូបង្រៀន ដោយឈរលើ "ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន" សម្រាប់អប់រំគ្រូបង្រៀន និងកម្មវិធីវិក្រឹតការគ្រូបង្រៀន។

ទាំងវិទ្យាស្ថានអប់រំគ្រូបង្រៀន ទាំងគ្រឹះស្ថានឧត្តមសិក្សាដែលមានកម្មវិធីអប់រំគ្រូបង្រៀនត្រូវមានបេសកកម្មសម្របសម្រួលដំណើរការបង្រៀន និងរៀន ដើម្បីឱ្យគរុនិស្សិតទទួលបានចំណេះដឹង មុខវិជ្ជា ជំនាញគរុកោសល្យ និងតម្លៃអប់រំ ដើម្បីបំពេញសេចក្តីត្រូវការក្នុងវិជ្ជាជីវៈជាគ្រូបង្រៀន។ គ្រូបង្រៀនត្រូវ

ទទួលបានការអប់រំដែលនឹងធានាបានថា គ្រូបង្រៀនមានសមត្ថភាពសម្របសម្រួលការសិក្សារបស់សិស្ស ឱ្យទទួលបានកញ្ចប់សមត្ថភាពភាព ដូចមានចែងក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាឆ្នាំ២០១៦ ដូចខាងក្រោមនេះ៖

- សមត្ថភាពអក្ខរសាស្ត្រនិងលេខសាស្ត្រ
- សមត្ថភាពភាសាបរទេស
- សមត្ថភាពបច្ចេកវិទ្យាព័ត៌មាននិងគមនាគមន៍ ( ICT)
- បំណិនប្រាស្រ័យទាក់ទងនិងធ្វើការងារជាក្រុម
- បំណិនពិចារណានិងការបង្កើតថ្មី
- បំណិនអនុវត្តចំណេះដឹងនិងជំនាញ
- បំណិនអភិវឌ្ឍបុគ្គល គ្រួសារនិងសង្គម
- បំណិនសហគ្រិនភាពនិងភាពជាអ្នកដឹកនាំ។

## ២. ស្តង់ដា

ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន មានគោលបំណងធានាឱ្យមានការអភិវឌ្ឍការអប់រំគ្រូបង្រៀនជាប្រព័ន្ធ ដើម្បីលើកកម្ពស់គុណភាពអប់រំគ្រប់កម្រិត និងមានវិសាលភាពគ្របដណ្តប់លើស្តង់ដា៨។

## ស្តង់ដាទី ១៖ ស្តង់ដាគ្រឹះស្ថាន

គ្រឹះស្ថានឧត្តមសិក្សា ដែលអាចផ្តល់កម្មវិធីអប់រំគ្រូបង្រៀន ត្រូវទទួលវិញ្ញាបនបត្រទទួលស្គាល់គុណភាពអប់រំពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (គ.ទ.ក) និងទទួលបានការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**វិទ្យាស្ថានជាតិអប់រំ** ត្រូវទទួលវិញ្ញាបនបត្រទទួលស្គាល់គុណភាពអប់រំពីគណៈកម្មាធិការទទួលស្គាល់គុណភាពគុណភាពអប់រំនៃកម្ពុជា ( គ.ទ.ក) និងទទួលបានការអនុញ្ញាតពីពីក្រសួងអប់រំ យុវជន និងកីឡា មុននឹងអាចផ្តល់កម្មវិធីអប់រំគ្រូបង្រៀនផ្សេងៗទៀត បន្ថែមលើកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ តាមរូបមន្តបរិញ្ញាបូក + 1 ដូចបច្ចុប្បន្ន។

សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម សាលាគរុកោសល្យ និងវិក្រឹតការរាជធានី ខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យរាជធានី ខេត្ត នឹងត្រូវអភិវឌ្ឍឱ្យទៅជាគ្រឹះស្ថានឧត្តមសិក្សា ដែលមានឈ្មោះថា " **វិទ្យាស្ថានអប់រំគ្រូបង្រៀន**" ដោយត្រូវបំពេញតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងស្តង់ដាជាតិសម្រាប់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា។

**គ្រឹះស្ថានឧត្តមសិក្សា** ដែលបានទទួលវិញ្ញាបនបត្រទទួលស្គាល់គុណភាពអប់រំពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និង**វិទ្យាស្ថានអប់រំគ្រូបង្រៀន** មានសិទ្ធិបើកកម្មវិធីអប់រំគ្រូបង្រៀនមួយ ឬច្រើននៃកម្មវិធីអប់រំគ្រូបង្រៀនដែលមានចែងក្នុងស្តង់ដាទី ២។

## ស្តង់ដាទី ២៖ កម្មវិធីអប់រំគ្រូបង្រៀន

កម្មវិធីអប់រំគ្រូបង្រៀនត្រូវបង្កើតឡើង ដោយយោងលើឯកសារពាក់ព័ន្ធនានា និងភស្តុតាងគ្រប់គ្រាន់ ស្តីពីការអប់រំ និងការបណ្តុះបណ្តាលគ្រូបង្រៀន រាប់ទាំងមាត្រាពាក់ព័ន្ធក្នុងរដ្ឋធម្មនុញ្ញ ច្បាប់អប់រំ និង ឯកសារគោលនយោបាយនានារបស់រាជរដ្ឋាភិបាលកម្ពុជា។ រាល់កម្មវិធីអប់រំគ្រូបង្រៀនទាំងអស់ត្រូវរៀបចំ តាមប្រព័ន្ធក្រេឌីត។

- កម្មវិធីអប់រំគ្រូបង្រៀនសម្រាប់មត្តេយ្យសិក្សា
- កម្មវិធីអប់រំគ្រូបង្រៀនសម្រាប់បឋមសិក្សា
- កម្មវិធីអប់រំគ្រូបង្រៀនសម្រាប់មធ្យមសិក្សាបឋមភូមិ
- កម្មវិធីអប់រំគ្រូបង្រៀនសម្រាប់មធ្យមសិក្សាទុតិយភូមិ។

## ស្តង់ដាទី ៣ គោលការណ៍កម្មវិធីសិក្សា

ដើម្បីធានាឱ្យការអប់រំគ្រូបង្រៀនមានគុណភាព កម្មវិធីទាំងអស់ត្រូវតែ៖

- ជាកម្មវិធីបរិញ្ញាបត្រអប់រំ ដែលមានជំនាញឯកទេសបង្រៀនតាមភូមិសិក្សា និងមុខវិជ្ជា ឯកទេស និងជំនាញអប់រំផ្សេងៗ
- អនុវត្តតាមសេចក្តីសម្រេច០៤/ ០៤ស្តីពីប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីត ចុះថ្ងៃទី១៩ ខែ វិច្ឆិកា ឆ្នាំ២០០៤ នៃគណៈកម្មាធិការទទួលស្គាល់គុណភាពគុណភាពអប់រំនៃកម្ពុជា
- មានភាពស៊ីគ្នា និងប្រទាក់ក្រឡាគ្នាជាលំដាប់ ដើម្បីធានាទំនាក់ទំនងប្រកបដោយប្រសិទ្ធ ភាពពីមួយឆ្នាំទៅមួយឆ្នាំ និងរវាងទ្រឹស្តីនិងការអនុវត្ត
- បញ្ចូលមុខវិជ្ជាភាសាអង់គ្លេស និងបច្ចេកវិទ្យាព័ត៌មានវិទ្យា
- បញ្ចូលកម្មសិក្សាវិជ្ជាជីវៈគ្រូបង្រៀនដែលមានតម្លៃមិនតិចជាង៥ ក្រេឌីត
- បញ្ចូលកិច្ចការស្រាវជ្រាវសរសេរសារណាដើម្បីបញ្ចប់ការសិក្សា ដែលមានតម្លៃមិនលើស ៦ ក្រេឌីត។

## ស្តង់ដាទី ៤៖ ធនធាននៃកម្មវិធី

គុណភាពនៃការស្រាវជ្រាវ ការបង្រៀន និងសេវាផ្សេងៗរបស់កម្មវិធីអប់រំគ្រូបង្រៀន គឺពឹងទាំង ស្រុងលើគុណវុឌ្ឍិ និងបទពិសោធន៍របស់សាស្ត្រាចារ្យ។ បន្ថែមលើវិញ្ញាបនបត្រនៃការទទួលស្គាល់គុណ ភាពអប់រំពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំកម្ពុជា គ្រឹះស្ថានដែលត្រូវផ្តល់កម្មវិធីអប់រំគ្រូបង្រៀន ត្រូវបង្ហាញអំពីភាពគ្រប់គ្រាន់ នៃធនធានមនុស្ស និងសម្ភាររូបវន្ត។ កម្មវិធីអប់រំគ្រូបង្រៀនត្រូវមាន៖

- សាស្ត្រាចារ្យដែលមានគុណវុឌ្ឍិស្មើកម្រិតអប់រំដែលត្រូវបង្រៀន ( បរិញ្ញាបត្រ/ បរិញ្ញាបត្រ ជាន់ខ្ពស់/ បណ្ឌិត) និងមានបទពិសោធន៍បង្រៀនយ៉ាងតិច ៥ ឆ្នាំ មានចំនួនមិនលើស ពី ៥០ ភាគរយ នៃសាស្ត្រាចារ្យដែលបង្រៀននៅក្នុងកម្មវិធី

- សាស្ត្រាចារ្យដែលមានគុណវុឌ្ឍិលើកម្រិតអប់រំដែលត្រូវបង្រៀន ( បរិញ្ញាបត្រជាន់ខ្ពស់/បណ្ឌិត) និងមានបទពិសោធន៍បង្រៀនយ៉ាងតិច ៣ឆ្នាំ មានចំនួនយ៉ាងតិច៥០ ភាគរយនៃសាស្ត្រាចារ្យក្នុងកម្មវិធី
- គ្រូបង្រៀនដែលមានគុណវុឌ្ឍិស្មើកម្រិតកម្មវិធីដែលត្រូវបង្រៀន ប៉ុន្តែមានបទពិសោធន៍តិចជាង៥ឆ្នាំ អាចធ្វើជាគ្រូជំនួយក្នុងកម្មវិធីអប់រំគ្រូបង្រៀន
- សាស្ត្រាចារ្យត្រូវមានសមត្ថភាពប្រើប្រាស់ភាសាអង់គ្លេស បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយអប់រំដើម្បីឆ្លើយតបនឹងតម្រូវការនៃការងារបង្រៀន
- កម្មវិធីអប់រំគ្រូបង្រៀនដែលបង្ហាញអំពីភាពគ្រប់គ្រាន់នៃធនធានបរិក្ខារ សម្រាប់ផ្តល់សេវាអប់រំគ្រូបង្រៀនដូចជា ៖
    - ថ្នាក់រៀន បន្ទប់បុគ្គលិក មណ្ឌលធនធាន ( ម៉ាស៊ីនថតចម្លង សម្ភារសម្រាប់ផលិតសម្ភារឧបទេស) សម្រាប់បម្រើគោលបំណងនៃកម្មវិធីការអប់រំ
    - ផលធៀបគ្រូសិស្សស្របតាមស្តង់ដាកំណត់របស់ (គ.ទ.ក)
    - បណ្ណាល័យរូបវន្ត និងទូរនិមិត្ត ( E-library) បន្ទប់ពិសោធន៍ ឧបករណ៍ និងសម្ភារពិសោធន៍សម្រាប់ដំណើរការបង្រៀន ការរៀន និងស្រាវជ្រាវ
    - ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ដើម្បីបម្រើទាំងគោលបំណងរដ្ឋបាល និងសម្រាប់បុគ្គលិក និងគរុនិស្សិតប្រើប្រាស់បម្រើការបង្រៀន រៀន និងការស្រាវជ្រាវឱ្យមានប្រសិទ្ធភាព
- កម្មវិធីអប់រំគ្រូបង្រៀនត្រូវធានាថា ធនធានបរិក្ខារ គឺអាចប្រើប្រាស់បានដោយគរុនិស្សិតដែលមានតម្រូវការពិសេស។

## ស្តង់ដារទី ៥៖ ការជ្រើសរើសគរុនិស្សិត

គ្រឹះស្ថានឧត្តមសិក្សា និងវិទ្យាស្ថានអប់រំគ្រូបង្រៀនត្រូវមានយន្តការជ្រើសរើសនិស្សិតឱ្យចូលរៀនដែលមានតម្លាភាព និងយុត្តិធម៌ ដើម្បីធានាថា គរុនិស្សិតនឹងមានសមត្ថភាពលើផ្នែកទាំងបី គឺវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា គ្រប់គ្រាន់សម្រាប់បន្តការសិក្សាកម្រិតឧត្តមសិក្សា។

កម្មវិធីអប់រំគ្រូបង្រៀនត្រូវ ៖

- មានគោលការណ៍ អំពីលក្ខខណ្ឌនៃការជ្រើសរើសគរុនិស្សិតឱ្យចូលរៀន
- ទទួលបេក្ខជនដែលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និង/ឬមានគុណវុឌ្ឍិសមមូលសម្រាប់កម្មវិធីអប់រំគ្រូបង្រៀនសម្រាប់មត្តេយ្យសិក្សា បឋមសិក្សា និង/ឬអនុវិទ្យាល័យ

- កម្មវិធីអប់រំគ្រូបង្រៀនទទួលនិស្សិតដែលបានបញ្ចប់បរិញ្ញាបត្រ ត្រូវមានលទ្ធផលសិក្សា GPA ចាប់ពី ២.៥ និងត្រូវរៀនបន្ថែមយ៉ាងតិច ៣០ ក្រេឌីតសម្រាប់កម្មវិធីអប់រំគ្រូបង្រៀនសម្រាប់អនុវិទ្យាល័យ
- គ្រប់ការប្រឡងចូលរៀនក្នុងកម្មវិធីអប់រំគ្រូបង្រៀនទាំងអស់ត្រូវតែធ្វើឡើងដោយការប្រឡងសរសេរ
- ការទទួលស្គាល់ការសិក្សាពីមុន ឬការរៀបចំការផ្ទេរក្រេឌីត ត្រូវបានកំណត់ដោយកម្មវិធីអប់រំគ្រូបង្រៀន ដោយអនុលោមតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងសេចក្តីសម្រេច ០៤/ ០៤ ស្តីអំពីប្រព័ន្ធក្រេឌីត និងការផ្ទេរក្រេឌីត ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤
- កម្មវិធីអប់រំគ្រូបង្រៀនដែលមានបំណងទទួលសិស្សឱ្យចូលរៀនដែលមាននិទ្ទេសទាបជាង C ឬ GPA ទាបជាង 2.5 ត្រូវពិគ្រោះយោបល់សុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា ជាមុនសិន និងត្រូវរៀបចំយន្តការទំនុកបម្រុងគរុនិស្សិតឱ្យបានជិតដល់ក្នុងអំឡុងពេលសិក្សាដើម្បីធានាថាគរុនិស្សិតនឹងទទួលបានកញ្ចប់សមត្ថភាព ដូចការរំពឹងទុកក្នុងស្តង់ដា ៧។

## ស្តង់ដាទី ៦៖ សាលាអនុវត្តន៍ និងសាលាសហការ

កម្មសិក្សាវិជ្ជាជីវៈគ្រូបង្រៀនជាផ្នែកមួយសម្រាប់ពង្រឹងសមត្ថភាពរបស់គរុនិស្សិត ដោយរក្សាតុល្យការនៃទ្រឹស្តីដែលបានរៀន និងបទពិសោធន៍ក្នុងថ្នាក់រៀនជាមួយសិស្ស។

- កម្មវិធីអប់រំគ្រូបង្រៀនត្រូវមាន " សៀវភៅណែនាំស្តីពីកម្មសិក្សាវិជ្ជាជីវៈគ្រូបង្រៀន" ដែលមានសេចក្តីណែនាំលម្អិតអំពីលក្ខខណ្ឌ វិធាន និងនីតិវិធីសម្រាប់គរុនិស្សិតចុះធ្វើកម្មសិក្សានៅតាមសាលាអនុវត្តន៍ និងសាលាសហការ
- កម្មវិធីអប់រំគ្រូបង្រៀនត្រូវធានាបង្កើតទំនាក់ទំនងផ្លូវការជាមួយសាលារៀនសហការដែលពាក់ព័ន្ធទៅនឹងកម្មវិធីអប់រំ ដែលគ្រឹះស្ថានផ្តល់តាមកម្រិតសិក្សាដើម្បីសម្រួលឱ្យគរុនិស្សិតចុះទទួលបទពិសោធន៍វិជ្ជាជីវៈបង្រៀនជាក់ស្តែង
- គរុនិស្សិតទទួលឱកាសគ្រប់គ្រាន់ដើម្បីបង្កើតទំនាក់ទំនង បង្រៀន និងធ្វើសកម្មភាពសិក្សាផ្សេងៗទៀត ជាមួយសិស្សក្នុងភូមិសិក្សា ដែលដូចគ្នានឹងកម្មវិធីអប់រំដែលគរុនិស្សិតរៀននៅក្នុងស្តង់ដាទី ២
- កម្មវិធីអប់រំគ្រូបង្រៀន និងសាលារៀនសហការត្រូវធានាផ្តល់ទំនុកបម្រុង និងភាពងាយស្រួលដល់គរុនិស្សិត និងការដឹកនាំដោយសាស្ត្រាចារ្យដែលមានសមត្ថភាពគ្រប់គ្រាន់ និងមានបទពិសោធន៍យ៉ាងតិច ៥ ឆ្នាំក្នុងការបង្រៀន
- កម្មវិធីអប់រំ និងសាលារៀនសហការត្រូវណែនាំ ត្រួតពិនិត្យ និងវិនិច្ឆ័យសមត្ថភាពគរុនិស្សិតបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដោយអនុលោមតាមស្តង់ដាទី៣ អមដោយ

របាយការណ៍វាយតម្លៃគរុនិស្សិតដោយផ្អែកទៅតាមលក្ខណៈវិនិច្ឆ័យសត្យានុម័ត ដែលមានចែងក្នុង " សៀវភៅណែនាំស្ដីពីកម្មសិក្សាវិជ្ជាជីវៈគ្រូបង្រៀន"។

## ស្តង់ដាទី ៧៖ សមត្ថភាពគរុនិស្សិត

កម្មវិធីអប់រំគ្រូបង្រៀនត្រូវបង្ហាញថា គរុនិស្សិតក្រោយបញ្ចប់ការសិក្សាពីកម្មវិធីអប់រំគ្រូបង្រៀននឹងបំពេញបាននូវកញ្ចប់សមត្ថភាព ដូចមានចែងក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនកម្ពុជា និងស្តង់ដាសមត្ថភាពគ្រូបង្រៀនរបស់អាស៊ានក្នុងសតវត្សរ៍ទី ២១។

គរុនិស្សិតដែលបញ្ចប់ការសិក្សានឹង ៖

- អាចពន្យល់ និងប្រើប្រាស់ក្របខ័ណ្ឌកម្មវិធីសិក្សាជាតិ កម្មវិធីសិក្សាលម្អិតតាមមុខវិជ្ជា សៀវភៅសិក្សាគោល និងឯកសារជំនួយនៃការសិក្សា ការបង្រៀន និងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស
- ឱ្យតម្លៃ និងប្រើប្រាស់បរិបទសិស្ស ដើម្បីដឹកនាំការបង្រៀន និងរៀន ស្របតាមទម្លាប់ ឧបនិស្ស័យ ទេពកោសល្យ តម្រូវការពិសេស និងចំណាប់ចំណូលចិត្តរបស់សិស្ស
- អាចប្រើប្រាស់គម្រោងលំនាំបង្រៀន ការរៀបចំថ្នាក់រៀន និងកិច្ចតែងការបង្រៀន ដើម្បីបង្រៀនសិស្សឱ្យមានការចាប់អារម្មណ៍ និងមានភាពសប្បាយរីករាយក្នុងការសិក្សា
- អាចជួយសិស្សឱ្យផលិត និងប្រើប្រាស់ស្នាដៃសម្រាប់ដាក់តាំង និងប្រើប្រាស់ក្នុងសកម្មភាពរៀន និងបង្រៀន
- ចេះរៀបចំការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ការប្រមូល វិភាគ បកស្រាយ និងប្រើប្រាស់ទិន្នន័យដែលពាក់ព័ន្ធនឹងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សដើម្បីកែលម្អលទ្ធផលនៃការរៀន និងបង្រៀន
- អាចបង្កើត និងរក្សាទំនាក់ទំនងវិជ្ជមានជាមួយសិស្ស អាណាព្យាបាល និងសហគមន៍ ដើម្បីកៀរគរធនធានបម្រើឱ្យការបង្រៀន និងរៀនកាន់តែមានភាពល្អប្រសើរ
- អាចសរសេររបាយការណ៍វឌ្ឍនភាពនៃការបង្រៀន និងការរៀនរបស់សិស្សក្នុងថ្នាក់ រៀន សម្រាប់រាយការណ៍ទៅគណៈគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធ
- អាចបង្ហាញសមត្ថភាពក្នុងការគិតប្រកបដោយការច្នៃប្រឌិត ការឆ្លុះបញ្ចាំងគ្រប់ជ្រុងជ្រោយ ការត្រិះរិះ និងការដោះស្រាយបញ្ហា
- ទទួលស្គាល់ និងឱ្យតម្លៃចំពោះគណនេយ្យភាពនៃភារកិច្ចជាគ្រូបង្រៀន និងក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ដើម្បីគាំពារតម្លៃវិជ្ជាជីវៈគ្រូបង្រៀន ។

**ស្តង់ដាទី ៨៖ ការធានាគុណភាពផ្ទៃក្នុង**

- កម្មវិធីអប់រំគ្រូបង្រៀនត្រូវរៀបចំគោលការណ៍ណែនាំសម្រាប់កំណត់ និងវាយតម្លៃកម្មវិធីអប់រំគ្រូបង្រៀន
- កម្មវិធីអប់រំគ្រូបង្រៀនត្រូវបង្កើតយន្តការត្រួតពិនិត្យគុណភាពផ្ទៃក្នុង និងឆ្លើយតបទៅលើការធានាគុណភាពដែលត្រូវបានរៀបចំឡើងដោយភាគីពាក់ព័ន្ធផ្សេងៗ
- កម្មវិធីអប់រំបង្រៀនត្រូវប្រមូលព័ត៌មាន និងទិន្នន័យនានា ដូចជា ដំណើរការបង្កើតកម្មវិធី ដំណើរការបង្រៀន និងរៀន ការវាយតម្លៃមុខវិជ្ជា ការវាយតម្លៃលទ្ធផលសិក្សារបស់គរុនិស្សិត ការស្ទង់មតិគរុនិស្សិត ការស្ទង់មតិនិយោជក និងមតិយោបល់ពីភាគីពាក់ព័ន្ធ ទុកធ្វើជាភស្តុតាងសម្រាប់វាយតម្លៃកម្មវិធីអប់រំ
- កម្មវិធីអប់រំគ្រូបង្រៀនត្រូវរៀបចំរបាយការណ៍ស្វ័យវាយតម្លៃអំពីគុណភាព ការកែប្រែ ដូចជា បន្ថែម ឬបន្ថយមុខវិជ្ជា និងបញ្ហាប្រឈមនានា សម្រាប់ដាក់ជូនស្ថាប័នមានសមត្ថកិច្ច ពិនិត្យជារៀងរាល់ឆ្នាំ។

## ៣. នីតិវិធីផ្តល់អាជ្ញាប័ណ្ណដល់កម្មវិធីអប់រំគ្រូបង្រៀន

- គ្រឹះស្ថានសិក្សាដែលត្រូវបាទទួលស្គាល់ឱ្យបង្រៀនកម្មវិធីអប់រំគ្រូបង្រៀន ត្រូវដាក់ឯកសារលម្អិតអំពីកម្មវិធីអប់រំគ្រូបង្រៀន ដែលគ្រឹះស្ថានចង់បង្រៀនជូនទៅស្ថាប័នមានសមត្ថកិច្ច
- ស្ថាប័នមានសមត្ថកិច្ច ពិនិត្យមើលឯសារដែលខ្លួនបានទទួលយ៉ាងយកចិត្តទុកដាក់ និងធ្វើសេចក្តីសម្រេចលើសំណើរបស់គ្រឹះស្ថាន ថាតើត្រូវផ្តល់អាជ្ញាប័ណ្ណឱ្យគ្រឹះស្ថានបង្រៀន ឬមិនឱ្យបង្រៀនកម្មវិធីអប់រំគ្រូបង្រៀន ដោយអនុលោមតាមប្រកាស ឬអនុក្រឹត។

## ៤. ការទទួលស្គាល់គុណភាពអប់រំ និងបណ្តុះបណ្តាលកម្មវិធីអប់រំគ្រូបង្រៀន

កម្មវិធីអប់រំគ្រូបង្រៀននឹងត្រូវវាយតម្លៃទទួលស្គាល់គុណភាពដោយស្ថាប័នមានសមត្ថកិច្ច ដោយការប្រើប្រាស់ស្តង់ដាសម្រាប់វាយតម្លៃកម្មវិធីអប់រំគ្រូបង្រៀន។